# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍ស្តីពី

## ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង

## លើគំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន ហៀន ហៀក អ៊ិនវេសមេន និងក្រុមហ៊ុន ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ ស្ថិតនៅ ប្រាសាទបល្ល័ង្គ និងស្រុកស្ទោង ខេត្តកំពង់ធំ

Draft

កាលពីវេលាម៉ោងពីរ និងសាមសិបនាទី ថ្ងៃទីប្រាំពីរ ខែមិថុនាឆ្នាំពីរពាន់ដប់ នៅសាលាខេត្តកំពង់ធំមានបើកកិច្ចប្រជុំពិភាក្សាមួយលើបទបង្ហាញរបាយការណ៍ស្តីពី ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង លើគំរោងស្នើសុំធ្វើការអភិវឌ្ឍន៍ដំណាំកៅស៊ូ របស់ក្រុមហ៊ុន **ហៀន ហៀក អ៊ិនវេសមេន និង ក្រុមហ៊ុន ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ** មានទីតាំងស្ថិតនៅ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ និងឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំ ក្រោមអធិបតីភាព **ឯកឧត្តម ឈុន ឈន់** អភិបាលខេត្តកំពង់ធំ ។

សមាសសភាពអញ្ជើញចូលរួមមាន:

| | | |
|---|---|---|
| ១- ឯកឧត្តម | អ៊ុក សំអន | អភិបាលរងខេត្តកំពង់ធំ |
| ២- លោក | យក់ អឿន | អគ្គលេខាធិការរង សាលាខេត្ត |
| ៣- បណ្ឌិត | លី សុពណ៌-មុនី | នាយក GCF (Green Consultancy Firm) |
| ៤- លោក | លោក ហង្ស សុធីម | អភិបាលស្រុកស្ទោង |
| ៥- លោក | គីម អាន | អភិបាលស្រុកប្រាសាទបល្ល័ង្គ |
| ៦- លោក | អ៊ុង យិត | នាយរងខណ្ឌរដ្ឋបាលព្រៃឈើ |
| ៧- លោក | ម៉ក់ យុទ្ធដា | អនុប្រធានមន្ទីរកសិកម្ម |

៨- លោក អេង ប៊ុនឃឿន អនុប្រធាន មន្ទីរបរិស្ថានខេត្ត

៩- លោក ចាន់ វណ្ណា បុគ្គលិក GCF (Green Consultancy Firm )

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ឈុន ឈន់** អភិបាលខេត្តកំពង់ធំមានមតិសំណេះសំណាល និងថ្លែងបើកអង្គប្រជុំអោយដំណើរការរួមមានខ្លឹមសារដូចតទៅ :

**បណ្ឌិត លី សុពណ៌-មុនី :** ថ្ងៃនេះខ្ញុំរីករាយណាស់ដែលឯកឧត្តមបានអនុញ្ញាតឱ្យក្រុមហ៊ុនយើងខ្ញុំ ធ្វើបទបង្ហាញទៅលើរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម លើគំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន ុន **បៀន ហៀក អ៊ិនវេសមេន និង ក្រុមហ៊ុន ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ** មានទីតាំងស្ថិតនៅ ឃុំសាគ្រាម ស្រុកប្រាសាទ បល្ល័ង្គ និងឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំ ។ ក្រុមហ៊ុន **ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ.** ស្នើសុំដីសម្បទានសេដ្ឋកិចអភិវឌ្ឍន៍វិនិយោគលើផ្ទៃដី ទំហំ៧២៨៩ ហិកតា ដើម្បីដាំកៅស៊ូ ។ ចំណែកឯក្រុមហ៊ុន **បៀន ហៀកអ៊ីនវេសមេន** ស្នើសុំដីសម្បទានសេដ្ឋកិច្ចមានទំហំ ៤.៣៨៥ហិកតា មានភូមិសាស្ត្រស្ថិតនៅឃុំសាគ្រាម ស្រុកប្រាសាទបាល័ង្គ ខេត្តកំពង់ធំ ។

ខ្ញុំសូមជំរាបជូនឯកឧត្តមអភិបាលខេត្ត និងអស់លោកដែលជាអង្គភាពជំនាញ នៅទីនេះឱ្យបានជ្រាបផងដែរ អំពីស្ថានភាពដីនៅក្នុងតំបន់នោះ ដែលទីតាំងដីនេះស្ថិតនៅក្នុងដែនជំរកសត្វបឹងពែរ ដូចនេះហើយទើបនៅលើលិខិតបទដ្ឋានគឺក្រសួងបរិស្ថានជាអ្នកធ្វើការសំរេច និងមានចុះហត្ថលេខា ដោយរដ្ឋលេខាធិការជូសមុខឱ្យឯកឧត្តមទេសរដ្ឋមន្ត្រី និងហត្ថលេខាមួយទៀតគឺ មកពីទីស្តីការគណរដ្ឋមន្ត្រី។ ដែលក្រុមហ៊ុនទាំងពីរនេះជាក្រុមហ៊ុនសហព័ន្ធកៅស៊ូរបស់រដ្ឋាភិបាលវៀតណាម ដែលមានលោកឧកញ៉ា ឡេង រិទ្ធី ជាអ្នកឈរឈ្មោះ ដំណាងឱ្យក្រុមហ៊ុននេះ។ ថ្វីត្បិតតែទទួលបាន ស.ជ.ណ ពីទីស្តីការគណរដ្ឋមន្ត្រីមែន ប៉ុន្តែគោលការណ៍របស់ដីសម្បទានសេដ្ឋកិច្ច ចាំបាច់តំរូវឱ្យមានលទ្ធផលសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន នឹងសង្គមជាមុនសិនទើប ក្រុមហ៊ុនអាចដំណើរការទៅបានដោយរលូនសមស្រមតាមគោលការណ៍របស់រដ្ឋាភិបាល ដូច្នេះហើយទើបខាង ក្រុមហ៊ុនដែលមានលោកឧកញ៉ា ឡេង រិទ្ធី ជាតំណាងនេះបានមក ទំនាក់ទំនងជាមួយក្រុមការងារបច្ចេកទេស យើងខ្ញុំដើម្បីចុះសិក្សាវាយតំលៃអំពីទំហំនៃការប៉ះពាល់ទាំងនោះ។ ទន្ទឹមនោះ ក្រុមការងារ ជី ស៊ី អេហ្វ បានបញ្ជូនក្រុមការងារបច្ចេកទេសចំនួន ៣ក្រុមដែលមានជំនាញផ្សេងគ្នា ចុះធ្វើការសិក្សាអំពីបច្ចេកទេស និងធនធានធម្មជាតិនៅក្នុងតំបន់នោះ ដែលក្រុមទីមួយធ្វើការហោះហើរ ដោយថតយកនូវរូបភាពនៃត្រាទស្សន៍ ដែលរូបភាពមួយមានទំហំប្រមាណជាមួយពាន់ហិកតា ដែលស្ថានភាពគំរបព្រៃយើងថតពេលហោះហើរ យើងអាចផ្ទៀងផ្ទាត់បាននូវស្ថានភាពការប្រើប្រាស់ដីនៅក្នុងទីតាំងដែលក្រុមហ៊ុនស្នើសុំ តើបច្ចុប្បន្នមានការប្រើប្រាស់គឺរបៀបណា? ហើយក្រុមទីពីរ យើងបានបញ្ជូនបុគ្គលិកចុះទៅសិក្សាលើទីតាំងផ្ទាល់ដើម្បីថតយករូបភាពនៅក្នុងព្រៃផ្ទាល់ ដើម្បីធ្វើការប្រៀបធៀបជាមួយរូបភាពហោះហើរ ហើយក្រុមទីបីគឺការងារទាក់ទង

Draft

ទៅនឹងសង្គម ដែលក្រុមការងារធ្វើការជួបពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានដូចជាថ្នាក់ដឹកនាំភូមិឃុំស្រុក និងប្រជាជនក្នុងសហគមន៍ ដោយមិនមានអំណោយផលចំពោះការងារ ដែលក្នុងថ្ងៃទីបួនខែប្រាំពីរ ឆ្នាំពីរពាន់ដប់នឹងមានការសម្ភោធឱ្យឈូសឆាយជាផ្លូវការ។ ហើយនៅថ្ងៃទី១៨ ខែ០៦ឆ្នាំ២០១០ យើងនឹងដាក់ប្រជុំក្នុងក៏រិតបច្ចេក ទេសនៅក្រសួងបរិស្ថាន ហើយថ្ងៃទី២៨នឹងប្រជុំឆ្លងអន្តរក្រសួង។ ព្រោះក្រុមហ៊ុននេះមិនមែនជាក្រុមហ៊ុនឯកជនទេ គឺជាក្រុមហ៊ុនសហព័ន្ធកៅស៊ូវៀតណាមដែលត្រូវការដីរហូតដល់ដប់ម៉ឺនហិកតា ហើយដីរបស់ក្រសួងកសិកម្មមិនមានលទ្ធភាពគ្រប់គ្រាន់ទើបងាកមករកដីរបស់ក្រសួងបរិស្ថានវិញ ទើបដីនេះក្រសួងបរិស្ថានជាអ្នកសំរេច។

គោលបំណងនៃការវិនិយោគនៅលើដីម្បទាននេះគឺ បង្កើនផលិតភាពព្រៃលើផ្ទៃដីព្រៃកាប់បំផ្លាញវិចរិលក្នុងដីសម្បទាន តាមរយៈការអភិវឌ្ឍន៏ការដាំដើមកៅស៊ូជាចំការ និងជាលក្ខណៈកសិ-ឧស្សាហម្ម ដើម្បីពង្រីកព្រៃដែលបានបាត់បង់ដោយសារការកាប់បំផ្លាញកន្លងមកជំនួសដោយព្រៃដើមកៅស៊ូដាំជាចំការ ថែរក្សាព្រៃឈើសំដៅការការពារលំនឹងបរិស្ថានធម្មជាតិក្នុងតំបន់ដីសម្បទាន។ ចូលរួមចំណែកផ្អែកអភិវឌ្ឍន៏សេដ្ឋកិច្ចជនបទបង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋ ជាពិសេសប្រជាកសិករដែររស់នៅក្បែរតំបន់ដីសម្បទាន និងការជំរុញការកែច្នៃផលិតផលដើមឈើ និងដំណាំរួមផ្សំផ្សេងៗទៀតសំរាប់តំរូវការទីផ្សារ និងធ្វើការនាំចេញទៅលើទីផ្សារអន្តរជាតិ។

លទ្ធផលនៃការស្រាវជ្រាវ គឺយើងចង់និយាយអំពីលក្ខណៈរូបរបស់ដី ក្នុងទីតាំងនីមួយៗមានលក្ខណៈយ៉ាងដូចម្ដេច? នៅលើទីតាំងដីទីមួយមានសិលាមេបីប្រភេទ ដែលប្រភេទសិលាមេទាំងនេះជាប្រភេទដីអាស៊ីតហើយយើងអាចធ្វើការសន្និដ្ឋានអំពីជីជាតិរបស់ដីនៅតំបន់នេះថា ជាដីមានជីជាតិទាប នេះយើងនិយាយតែដីស្រទាប់លើទេ តែចំពោះដីនៅស្រទាប់ក្រោមវិញគឺជាប្រភេទដីដែលសមប្រម និងដំណាំរុក្ខជាតិត្រូពិចដែលមានស្លឹកធំ ដូចនេះហើយទើបយើងចង់ធ្វើការប្រែក្លាយដីនៅតំបន់នេះទៅជាចំការកៅស៊ូ។ បើនិយាយអំពីឋានលេខាដីទាំងពីរក្រុមហ៊ុននេះមានស្ថានភាពរាបស្មើរ ដែលវាបង្កលក្ខណៈងាយស្រួលដល់ការឈូសឆាយ និងដាំដុះព្រោះផ្ទៃដីលើសពី៩៩% គឺមានមុំចាប់ពីសូន្យទៅប្រាំដឺក្រេ លើកលេងតែក្រហមឆ្នូតៗនេះវាអាចជាទួលខ្ពស់ដែលមានមុំប្រាំដឺក្រេ តែយើងអាចធ្វើការឈូសឆាយទាំងអស់ អាចដាំកៅស៊ូបានទាំងអស់ព្រោះដីនៅតំបន់ទាំងពីរនេះមិនមានចំរ៉ាក់ចោទដែលឱ្យយើងពិបាកឈូសឆាយនោះគឺអត់មានទេ។ មកដល់ចំណុចនេះខ្ញុំចង់ជំរាបជូនឱ្យថ្នាក់ដឹកនាំខេត្ត អំពីស្ថានភាពគំរបព្រៃ (លក្ខណៈដាយណាមិករបស់ព្រៃ) ដំណើរប្រែប្រួលរបស់គំរបព្រៃនិងការប្រើប្រាស់ដីនៅក្នុងតំបន់ហ្នឹង ដែលយើងប្រើប្រាស់ប្រព័ន្ធទិន្នន័យបួនជំនាន់ ដែលពីរជំនាន់របស់ UNDP និងពីរជំនាន់ទៀតរបស់រដ្ឋបាលព្រៃឈើ ដែលសហការណ៍ជាមួយ CTZ ធ្វើការបកស្រាយគំរបព្រៃតាមរយៈរូបភាពផ្ដល់ឱ្យដោយផ្កាយរណប។ រូបនេះគឺជាផែនទីកាលពីឆ្នាំ១៩៩២-១៩៩៣ ដែលមានរយៈពេល

កាលពី១៨-១៩ឆ្នាំមុននេះគឺបង្ហាញថា ស្ថានភាពផែនទីនេះគឺមិនមានបែងចែកគំរបព្រៃច្រើនប្រភេទទេ ដែលតាមភាសាបច្ចេកទេសហៅថា ការកំណត់និយមន័យអំពីសហព័ន្ធរុក្ខជាតិនៅតំបន់នោះ អត់មានបែងចែកច្រើនទេឱ្យតែដីមានព្រៃយើងកំណត់ដីមានគំរបព្រៃទាំងអស់ តែជាក់ស្តែងដីទាំងអស់នេះដូចជាលោកពូអភិបាលខេត្តក៏ធ្លាប់ដឹកនាំគ្រប់គ្រងនៅតំបន់នេះ លោកអភិបាលស្រុកក៏ធ្លាប់ដឹកនាំ នៅតំបន់នេះដូចគ្នាដែរ ថ្នាក់ដឹកនាំទាំងអស់សុទ្ធតែធាប់ដូចគ្នា សូម្បីតែខ្ញុំក៏ជាអ្នកកំពង់ធំនេះដែរ ដូច្នេះហើយយើងសុទ្ធតែដឹងថាព្រៃនៅតំបន់បឹងពែរនេះគឺជាព្រៃស្រោងទាំងអស់ ដូចនេះទោះបីជាមិនមានការបកស្រាយពីសារព័ន្ធរុក្ខជាតិច្រើនប្រភេទក្តី ប៉ុន្តែយើងទាំងអស់គ្នាដឹងថាព្រៃទាំងអស់នោះសុទ្ធតែជាព្រៃស្រោងទាំងអស់។ អញ្ចឹងយើងក្រឡេកមកមើលផែនទីគំរបព្រៃឆ្នាំ១៩៩៧វិញម្តងរបស់ UNDP ដដែល អញ្ចឹងយើងឃើញថាពិណបែតងទាំងអស់ដែល យើងឱ្យនិយមន័យថាដីដែលមានគំរបព្រៃ នេះចំពោះក្រុមហ៊ុន បៀន ហៀក ចំពោះក្រុមហ៊ុន C.R.C.K.2 នេះ ក៏មានតែមួយប្រភេទដូចគ្នា តែបើយើងមើលទៅលើផែនទីនេះគឺយើងមើលអត់ដឹងទេ យើងអាចថាមានដីកសិកម្ម អាចថាមានបងប្អូនយើងនៅឃុំពពកនឹងគាត់ទៅកាប់ឆ្ការព្រៃ ដែលយើងអាចហៅថាជាចំការពនេចរ បើនៅឥណ្ឌូនេស៊ី គេហៅថាចំការស្រូវដាំបានន័យថា គោកាប់ព្រៃហើយគេដាំស្រូវ ដាំពោត ល្ពៅ ននោង អីហ្វូរហែរតាមនឹងទៅ សរុបសេចក្តីមកគឺមានតែសាពវ័ន្ធរុក្ខជាតិតែមួយប្រភេទដូចគ្នា អញ្ចឹងយើងមកមើលឆ្នាំ២០០២បានន័យថាចន្លោះពី៦-៧ឆ្នាំក្រោយនឹងការប្រើប្រាស់ដីនេះវាមានលក្ខណៈដូចម្តេច? នៅក្នុងដីឃុំពពកមានសាព័ន្ធរុក្ខជាតិចំនួន៣ប្រភេទ ភាគច្រើនគ្របដណ្តប់ទៅដោយព្រៃស្រោងដដែល ព្រៃពាក់កណ្តាលស្រោង៣៤ហើយដីដែលគ្មានព្រៃនឹង៨៤សរុបប្រមាណតែជាងមួយភាគរយទេហើយដីដែលគ្មានព្រៃនឹង៨៤ហិកតាសរុបប្រមាណតែជាងមួយភាគរយ ហើយដីដែលគ្មានព្រៃនេះនៅក្នុងតំបន់ប្រហែលជាដីចំការរបស់បងប្អូនប្រជាជនមូលដ្ឋានឆ្ការធ្វើការដាំដុះ ព្រោះក្រៅពីការកាប់ធ្វើការដាំដុះយើងមិនប្រើប្រាស់ដីនោះក្នុងផលប្រយោជន៍អ្វីផ្សេងទៀតទេ។ បើក្រឡេកមើលនៅក្នុងភូមិសាគ្រាមរបស់យើងវិញសហព័ន្ធរុក្ខជាតិ សរុបមានចំនួនប្រាំប្រភេទផាគច្រើន៩៩ភាគរយគ្របដណ្តប់ទៅដោយព្រៃស្រោង ដែល៣៨ហិកតា យើងចាត់ទុកថាជាដីកសិកម្ម ចំណែកឯ៥៨ហិកតា យើងចាត់ទុកថាជាវាលស្មៅ និង៣១៣ ហិកតាទៀត យើងចាត់ទុកថាជាដីព្រៃគុម្ពោធ មានថែមមួយទៀត២២ហិកតា ជាផ្ទៃទឹកអាចថាជាបឹង ខ្ញុំសូមធ្វើការបញ្ជាក់បន្ថែមទៀតទៅលើសារព័ន្ធរុក្ខជាតិបី ដែលជាដីកសិកម្ម ដីវាលស្មៅ និងព្រៃកុម្ពោធ យើងអាចយល់បានថា ដីទាំងអស់នេះ សុទ្ធតែជាដីកសិកម្ម ទាំអអស់ ប៉ុន្តែតែដោយរូបភាពផ្កាយរណបនេះថតនៅរយៈកំពស់ខ្ពស់៦គ.ម ពីផ្ទៃដីទេ ដូចនេះការវិភាគពណ៌ដែល ឱ្យមកវាអត់មានលក្ខណៈលំអិតច្បាស់លាស់ទេ ដោយមិនមានភាពចំបាច់គាត់ក៏មិនបានចុះមកធ្វើការផ្ទៀងផ្ទាត់គាត់បានដាំ។ ចំណែកឯដីដែលយើងហៅថាស្រប់លេន (ព្រៃគុម្ពោធ) អាចថាជាចំការដែលបងប្អូនគាត់ដាំហើយគាត់ចោលពីរឆ្នាំជាព្រៃបុស្ស អញ្ចឹងនៅក្នុងរូបភាពផ្កាយរណបគេឱ្យឈ្មោះថាជាព្រៃគុម្ពោធ អញ្ចឹងអាចថាពី៨-៩ឆ្នាំមុននឹង ៤០០ហិកតានេះ ប្រើប្រាស់ជាដីកសិកម្មរួចស្រេចទៅហើយជាក់ស្តែងដូច ខ្ញុំចុះទៅនឹងឃើញ

Draft

ថាមានចំការស្វាយចន្ទី មួយចំនួនវាមានអាយុ៦-៧ឆ្នាំបាត់ទៅហើយដល់ពេលផ្កាយរណបវាប្រាប់ថាព្រៃគុម្ពោធទៅវិញ អញ្ចឹងយើងត្រឡប់មកមើលគំរបព្រៃឆ្នាំចុងក្រោយនៅក្នុងតំបន់នោះនៅឃុំពពកមិនមានការផ្លាស់ប្តូរច្រើនទេ មានតែ២ប្រភេទដដែល ដីគ្មានគំរបព្រៃ និងដីព្រៃស្រោង ដីមានគំរបព្រៃនៅតំបន់នេះវាស្ថិតនៅផ្នែកខាងលិចជ្រុងខាងត្បូង ហើយនឹងឈាងខាងលិចនៅតំបន់នឹងវាគៀកសហគមន៍ឃុំពពក ។ ដូចនេះយើងអាចយល់ថាដីគ្មាន ព្រៃហ្នឹងត្រូវបានប្រើប្រាស់ក្នុងទិសដៅកសិកម្មទាំងអស់ ។ ដោយឡែកចំពោះឃុំសាគ្រាមវិញការប្រើប្រាស់ដីគឺ មានលក្ខណៈរាលដាល ដីព្រៃពាក់កណ្តាលស្រោង និងដីបើកចំហខ្លាំង សរុបមានផ្ទៃដីប្រមាណជា ១000ហិកតា អញ្ចឹងការប្រើប្រាស់ដីនៅក្នុងទីតាំងក្រុមហ៊ុនបៀនហៀកនេះមាន ការប្រែប្រួលខាំងជាងដីនៅក្នុងឃុំពពកស្រុកស្ទោង ។ ហើយចំណែកដីគំរបព្រៃ២ឆ្នាំចុងក្រោយយើងឱ្យនិយមន័យ ដីព្រៃស្រោងដូចនេះបើយើងមើលសសានភាពព្រៃយើងឱ្យនិយមន័យ ដូច្នោះយើងត្រឡប់មកមើល និងសិក្សាអំពីការប្រើប្រាស់ដីនិងគំរបព្រៃចុងក្រោយ ការប្រើប្រាស់ដីយើងមិនអាចមកស្រាយបានទេព្រោះការហោះហើរនេះគឺក្រុមហ៊ុនឯកជនគឺ យើងមិនអាចហោះហើរមើលពីការប្រើប្រាស់ដីពីឆាំ២00៦មកឆ្នាំ២0១0មានការប្រែប្រួលដូចម្តេចនៅក្នុងតំបន់និមួយៗហ្នឹងយើងត្រូវការហោះ១00% ហើយយើងមកស្រាយវាទៀតទាមទារលុយច្រើនហើយប្រើពេលវេលាវែង ធម្មតាថតមួយប៉ុស្តិ៍នេះមានមួយគីឡូម៉ែត្របួនជ្រុង អាចនិយាយបានថា១00ហិកតាវាអស់២00ដុល្លា ហើយត្រូវធ្វើការបកស្រាយវាយន្តភាពដីដែលចាំបាច់ត្រូវចុះទៅដល់ទីតាំង ដើម្បីពិនិត្យមើលថាវាមានអ្វីខ្លះ ពិនិត្យមួយៗដើម្បីធ្វើការបកស្រាយវា ដូច្នេះក្រុមហ៊ុនឯកជនគេមិនងាចធ្វើឱ្យយើងបានទេ អញ្ចឹងសំខាន់យើងគ្រាន់តែចង់បង្ហាញថា តើគំរបព្រៃដែលយើងអោយនិយមន័យបៃតង ជាព្រៃស្រោងវាយ៉ាង ម៉េច?ពាក្យថាព្រៃស្រោង យើងបែងចែកដែលអាចនៅក្នុងនេះមានបងៗដែលជាជំនាញរដ្ឋបាលព្រៃឈើ អញ្ចឹងគាត់អាចយល់ច្បាស់ថែមទៀត នៅក្នុងព្រៃស្រោងយើងអាចបែងចែកជាព្រៃមិនទាន់បានរំខានយើងអាចហៅថា ជាព្រៃឡង់ ព្រៃក្រមុំអីជាដើម ។ អញ្ចឹងបើសិនជាព្រៃស្រោងយើងចូលទៅដល់ក្នុងព្រៃនោះគឺយើងមើលថ្ងៃមិនឃើញមេឃបានទេ។ ព្រៃស្រោងនៅកំពង់ធំនេះកាលពី២0ឆ្នាំមុនខ្ញុំអត់បានចូលទេនៅតំបន់នេះប៉ុន្តែ ដូចសម័យប៉ុលពតខ្ញុំទៅឃ្វាលគោ ក្របីនៅបាសាទ ត្រពាំងព្រីងឡើងទៅក្បាលដំរី ឬស្សីព្រៃ ឡើងទៅទីរីង ភ្នំជី ព្រៃហ្នឹងគេហៅព្រៃឡង់ចំតួតែម្តង អញ្ចឹងយើងមើលទៅលើគឺអត់ឃើញមេឃតែម្តង ហើយដោយសារថាដីវាមានជីជាតិ ដូចនេះវាមានកម្ពស់រហូតដល់៣៥-៤៥ម. ហើយកន្លែងណាខ្ពស់រហូតដល់ ៦0ម៉ែត្រហើយឈើដែលខ្ពស់ហ្នឹង មានតែឈើទាល ផ្ចឿកទេ ដែលលូតខ្ពស់ដាច់នោះ ចំណែកឯប្រភេទឈើប្រណិតឈើលេខមួយគឺមិនអាចលូតទៅខ្ពស់បានទេ ដូចនេះនៅពេលដែលមានការប្រើប្រាស់ យើងដកស្រទាប់ព្រៃមាន៣-៤ស្រទាប់អញ្ចឹងបើយើងមើលថាព្រៃស្រោងមានការរំខាន ឬក៏ជាព្រៃស្រោងរេចរិលហ្នឹងយើងត្រូវដកពី Canopy របស់វា៤ស្រទាប់ នោះយើងគ្រាន់តែកំណត់និយមន័យថា ព្រៃនេះវាយ៉ាងម៉េច? យើងមើលរូមភាពនៃត្រាទស្សន៍ ទោះបីយើងដឹងថារូបភាពនេះមិនមានទីតាំងនិងចំណុចនិយាមកាច្បាស់លាស់មែន តែរូបភាព

Draft

នេះប្រាកដច្បាស់ថាយើងថតនៅតំបន់នឹងហើយ អញ្ចឹងយើងមើលព្រៃនេះគឺសុទ្ធតែជាព្រៃស្រោងរេចរិលគឺយើងផ្តោតធ្ងន់ ទៅលើការប្រើប្រាស់លក្ខណៈពាណិជ្ជកម្ម ជាទូទៅឈើដែលអាចដកហូតបាននោះគឺវាបាត់បង់ច្រើនមែនទែន ហើយតាមខ្ញុំបានចូលទៅដល់ហ្នឹងជាទូទៅ នៅពេលដែលគេដកឈើផ្ចៀក អញ្ចឹងយើងដឹងថាតើភាពរិចរិលរបស់ព្រៃស្រោងវាដល់កំរិតណា? ធម្មតាអត់ប្រើទេ នៅពេលដែលឈើនៅតំបន់នោះនៅមានឈើប្រភេទលេខ២ គេចាប់ផ្តើមប្រើឈើទាលអស់សិន លុះត្រាតែប្រើឈើទាលអស់ទើបគេប្រើឈើផ្ចៀក នៅពេលប្រើឈើក្រៅចំណាត់ថ្នាក់អស់ហើយ ចុងក្រោយព្រៃតំបន់នោះ ក្លាយទៅជាព្រៃអុស ដូចនេះព្រៃនៅតំបន់នោះលែងមានឈើមានតំលៃពាណិជ្ជកម្មហើយ ។ ប៉ុន្តែយើងមើលទៅលើព្រៃនេះ យើងនៅមានតំលៃច្រើនឬតិច ។

**ឯកឧត្តមអភិបាលខេត្ត :** អាឡោះស័យខ្ញុំសូមធ្វើកាត់អត្ថាធិប្បាយបន្តិច សុំឱ្យនិយាយអំពីផលប៉ះពាល់ នៅនឹងទីតាំងដីដែលស្នើសុំនេះ ប៉ះពាល់អីខ្លះ? ហើយក្រុមការងារដែលចុះទៅសិក្សានេះឃើញមានអ្វីខ្លះ ដើម្បីដកមកពិភាក្សាគ្នា រួមគ្នាធ្វើការដោះស្រាយ ។ អារឿងបច្ចេកទេសនៃការគ្រប់គ្រងព្រៃឈើ ទុកឱ្យជំនាញគេធ្វើការចុះឥឡូវយើងបង្ហាញពីផ្ទៃដី១៥០០០ហិកតា តើវាមានផលប៉ះពាល់នឹងប្រជាពលរដ្ឋអ្វីខះ? ហើយក្រោយពីក្រុមការងារបច្ចេកទេសរាយការណ៍ចប់ សុំឱ្យស្រុក និងជំនាញពាក់ ធ្វើការរាយការណ៍បន្ថែម ដើម្បីពិភាក្សាការកដំណោះស្រាយ ។

**បណ្ឌិត លី សុពណ៌-មុនីៈ** សូមអគុណ មុននឹងដល់ចំណុចដែលឯកឧត្តមមានប្រសាសន៍ ខ្ញុំសូមធ្វើការបកស្រាយបន្តិចទៀត មូលហេតុអីបានជាខ្ញុំធ្វើការបកស្រាយមកតាមលំដាប់លំដោយអញ្ចឹងនោះ ព្រោះជាគោលការណ៍ព្រៃស្រោងគឺយើងមិនអាចប្រគល់ឱ្យក្រុមហ៊ុនធ្វើការប្រើប្រាស់ទេនេះជាគោលការណ៍របស់រាជរដ្ឋាភិបាល ការបកស្រាយនេះដើម្បីចុងក្រោយយើងទាញជាសម្មិកម្មមកវិញថា តើគួរយើងអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍន៍ ឬមិនធ្វើការអភិវឌ្ឍន៍អញ្ចឹងយើងប្រាប់ពីតំលៃរបស់ព្រៃ មូលហេតុហ្នឹងហើយបានមានការមកស្រាយ ។ ប៉ុន្តែអញ្ចឹងខ្ញុំសូមកាត់ត្រឹមហ្នឹង ខ្ញុំលែងបកស្រាយបញ្ជាក់របព្រៃ តែសុំចូលទៅបន្តិចទៀតព្រោះអីវាជិតដល់ចប់ហើយ ព្រោះអីវាមានការទាក់ទងគ្នា នេះជារូបភាពរបស់ក្រុមហ៊ុន C.R.C.K.2 យើងបានជ្រើសរើសយកឡូតិ៍គំរូ ចំនួន២៩ សូមឯកឧត្តមជ្រាបថា ព្រៃស្រោងដែលយើងបានចូលទៅនេះ ឃើញថាមានមានស្ថានភាពព្រៃអញ្ចឹង យើងឃើញមានគល់មួយដែលគល់នេះអាចថាជាគល់ផ្ចៀក ហើយវាអាចកាត់មកប៉ុន្មានឆ្នាំហើយហើយចេះតែបន្តកាប់ទៀតទៅ ដែលចុងក្រោយវានៅសល់តែព្រៃដូចដែលបានបង្ហាញនៅពេលនេះអញ្ចឹង ប៉ុន្តែសំណាកនេះប្រាប់ថាវាគឺជាព្រៃស្រោង តែឡូតិ៍មួយនេះឃើញមានដើមឈើទាលផងដែរ នេះប្រហែលជារណ្តៅជ័រ នេះដោយសារម្ចាស់ជ័រចេញចូលទៅដងជ័រញឹកញាប់អញ្ចឹងហើយទើបនៅសល់ ហើយព្រៃនៅតំបន់នេះកាលពី ២០ឆាំមុនសុទ្ធតែជាព្រៃស្រោង ដើយឈើពាណិជ្ជកម្មវាដូចម្រាមដៃមួយហិកតាយ៉ាងហោចណាស់ក៏មាន២០-៣០-ដើមដែរ ហើយមួយដើមចម្ងាយពី២៥-៣៥ម៉ែត្រគូបឯនោះ ។ ដូចនេះព្រៃនេះពេលយើងចូល

ទៅគឺអត់មានទេ នេះមានផ្សៀក មួយដុំនេះទើបនឹងផៃហើយ ជាក់ស្តែងយើយចូលទៅឆាប់បានត្រអំសើន័រមួយគ្រឿង ខ្ញុំមិនមែនអ្នកចាប់ទេ សមត្ថកិច្ចអ្នកចាប់ទេខ្ញុំចូលទៅពឹងគាត់ឱ្យជូនទៅ ពេលចូលទៅដល់ជួបគត់ក៏ចាប់ទៅ។ ហើយកន្លែងខ្លះយើង ឃើញទើបតែមានការកាប់ដុតដាំស្រូវ ពោត ថ្មី។ អញ្ចឹងខ្ញុំសូមធ្វើការបកស្រាយធនធានអេកូឡូស៊ីតែប៉ុណ្ណឹង។ សូមនិយាយអំពីផលប៉ះពាល់វិញម្តង យើងសុំលើកយកក្រុមហ៊ុន C.R.C.K.2 ហើយ លោកពូដែលជាអភិបាលស្រុកស្នោងក៏មានវត្តមាននៅទីនេះស្រាប់ ប្រសិនបើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជន ក្រុមហ៊ុនមិនអាចធ្វើការឈ្ចូសឆាយរហូតដល់ទៅ ២៤០០ហិក តាមកនេះបានទេ បើសិននៅកន្លែងដទៃទៀតបើមិនមានការដោះស្រាយមានការធ្វើបាតុកម្ម ចលនាទៅផ្អាកសកម្មភាពមានសុទ្ធតែ កំបិតខ្វែវ ហើយជួនកាលក្នុងករណីធ្ងន់ធ្ងរ មានរហូតទៅដល់ដុតគ្រឿងចក្រទៅទៀតដោយឡែកក្រុមហ៊ុន C.R.C.K.2 មកដល់បច្ចុប្បន្នឈ្ចូសឆាយរហូតដល់ទៅ២៤០០ហិកតាហើយ តាមការរាយការណ៍ពីសហការីយើងខ្ញុំដែលបានចុះទៅដល់ទីនោះក្រុមហ៊ុនបានធ្វើការដោះស្រាយជាមួយប្រជាជននេះ តែដោយដីក្រុមហ៊ុននេះជាង ៧០០០ហិកតា ហើយក្រុមហ៊ុនទើបតែឈ្ចូសបាន២៤០០ហិកតា នៅជាង៥០០០ហិកតាទៀតនៅពេល ដែលក្រុមហ៊ុនឈ្ចូសឆាយក្រុមហ៊ុន និងធ្វើការដោះស្រាយយ៉ាងម៉េចយើងមិនដឹងថាម៉េចទេ។ ប៉ុន្តែយើងជឿ ជាក់លើក្រុមហ៊ុននេះមិនធ្លាន់មានប្រវត្តិជំលោះជាមួយប្រជាជនទេ ខ្ញុំលើកករណីធ្ងន់ធ្ងរមួយនៅឃុំប៊ូស្រា ស្រុកពេជជ្រាដា ខេត្តមណ្ឌលគិរី គឺជាតំបន់ដ៏ក្តៅបំផុតហើយ នៅពេលដែលក្រុមហ៊ុនបារាំងមួយសូរហ្វីនទៅគឺដុតដល់ ទៅគ្រឿងចក្រហើយចៅហ្វាយខេត្តនឹងរង្គោះរង្គើរទៀត ឯកឧត្តម កែវ ហន គាត់ក៏អ្នកស្រុកយើងនឹងដែរ គឺដោយសាររឿងនឹង ដោយឡែកជាប់ និងក្រុមហ៊ុនសូរហ្វីនដែរមានក្រុមហ៊ុនដាក់ឡាក់ដែលជាក្រុមហ៊ុនមួយ ស្ថិតនៅក្នុងសហព័ន្ធកៅស៊ូគាត់អត់មានបញ្ហាអ្វីទាំងអស់ខ្ញុំបានចុះទៅវាយតំលៃផាល់ហើយវិធីសាស្ត្រនៃនីតិវិធីរបស់ក្រុមហ៊ុននោះ គឺការអភិវឌ្ឍន៍របស់គាត់មានលក្ខណៈសហគមន៍បានន័យថាម៉េច? ពោះគាត់អភិវឌ្ឍន៍ខ្លួនឯងផង គាត់ចូលរួមចំណែកអភវឌ្ឍន៍សហគមន៍ផង កាលណាគាត់ឈ្ចូសទៅដល់កន្លែងណា បើមានបញ្ហាអី គាត់ស្រាវជ្រាវតាមរយៈអាជ្ញាធរមូលដ្ឋាន អ្នកណាមានបញ្ហាអីគាត់ហៅមកចរចារគ្នាតែម្តងបើម្ចាស់ដីពេញចិត្តថាលក់ ក៏លក់ទៅគាត់ទិញ បើមិនលក់ក្រុមហ៊ុនសួរថាចង់ដាំកៅស៊ូអត់ បើចង់ដាំក្រុមហ៊ុនឈ្ចូសឱ្យផ្តល់ពូជឱ្យ និយាថាម្នាំកំប្លេតែម្តង គ្រាន់តែមានកិច្ចសន្យាមួយថាដីរបស់គ្រួសារនឹងមានទំហំប៉ុន្មាន ធ្វើកិច្ចសន្យាដល់ពេលប្រមូលផលលក់ឱ្យក្រុមហ៊ុន ធ្វើដូច្នេះគឺគេដាំបានច្រើនមែនទៀត អញ្ចឹងហើយទើបទោះនូវកន្លែងណា គឺមិនធ្លាប់មានបពាដាអ្វីទាំងអស់ ខ្ញុំដឹងច្បាស់ព្រោះអីដី១០ម៉ឺនហិកតានឹងគឺខ្ញុំអ្នកចុះវាយតំលៃឱ្យទាំងអស់មិន ថានៅកំពង់ធំ មិនថានៅព្រះវិហារ មិនថានៅខេត្តក្រចេះ រតនគិរី ឬស្ទឹងត្រែងខ្ញុំវាយតំលៃឱ្យទាំងអស់ ដូចនេះ ខ្ញុំដឹងច្បាស់ថាក្រុមហ៊ុននេះមិនប៉ះពាល់ដីប្រជាពលរដ្ឋតែម្តង។ ទោះបីនៅក្នុងដំណាក់កាលនៃការវាយតំលៃដំបូងនេះ យើងមិនបានពេញលេញ១០០%ក្តី ប៉ុន្តែយើងជឿជាក់ថាអញ្ចឹង ព្រោះអីក្រុមហ៊ុនឈ្ចូសឆាយបានជាងពីរពាន់ហិកតាហើយមិនមានបញ្ហាអីឱ្យថ្នាក់ដឹកនាំខេត្តស្រុកឈឺក្បាលទេ។ ដោយ

Draft

ឡែកដីស្ថិតនៅឃុំសាគ្រាម វិញម្តង នៅពេលដែលខ្ញុំចូលទៅក្នុងដីនោះ ហើយខ្ញុំចូលទៅរហូតជិតដល់ដីឃុំពពក ហើយនៅពេលដែលខ្ញុំ ត្រឡប់មកវិញបានជួបនឹងប្រជាពលរដ្ឋ ដែលពួកគាត់ចូលទៅប្រមូលផលព្រៃឈើនៅតំបន់នោះ ហើយខ្ញុំក៏រៀបរាប់ប្រាប់ថាហេតុអីបានជាខ្ញុំចូលមកទីនោះ ថានឹងមានក្រុមហ៊ុនចូលមកធ្វើវិនិយោគដំកៅស៊ូអីនឹង គាត់ក៏បានសំណូមពរខ្ញុំសុំឱ្យក្រុមហ៊ុនធ្វើការរំកិលព្រំដីឱ្យបាន៤គ.ម ។ តែក្រុមហ៊ុនមិនរំកិលបានទេ ព្រោះអីក្រុមហ៊ុនបានកំណត់ទីតាំងរួចហើយ ហើយចេញទាំង ស.ជ.ណ.ទៀត តែដោយសារតែក្រុមហ៊ុនខ្លួនឯងមិនមានបំណងធ្វើអ្វី បំពានធ្វើអ្វីឱ្យប៉ះពាល់ប្រជាជននៅក្នុងមូលដ្ឋាន អញ្ចឹងខ្ញុំក៏ធ្វើការបញ្ជាក់ប្រាប់ពួកគាត់ថា បងប្អូនគួរណាតែពិចារណាឡើងវិញ ថាតើយើងបន្តធ្វើស្រូវ ឬមួយដាំចន្ទីទៀត ឬមួយក៏ធ្វើការផ្លាស់ប្តូរគំនិតថ្មីវិញថា នៅពេលដែលក្រុមហ៊ុនមកអនុវត្តន៍ដាំដើមកៅស៊ូ បើបងប្អូនមានដីច្រើន ដីមួយចំនួនយើងទុកទៅសំរាប់ធ្វើស្រែ ហើយមួយផ្នែកធំយើងគួរកែបែរទៅចំការដាំកៅស៊ូ បើដីដែលនៅក្នុងក្រុមហ៊ុនបងប្អូនចង់ដោះដូរឱ្យក្រុមហ៊ុនក៏បាន បើមិនចង់ដោះដូរទេ បងប្អូនចង់ដាំកៅស៊ូក្រុមហ៊ុនធ្វើការឈូសឆាយដាំឱ្យគ្រាន់តែធ្វើកិច្ចសន្យាពេលប្រមូល ផលត្រូវលក់ឱ្យក្រុមហ៊ុនវិញ ខ្ញុំបានធ្វើការអះអាងប្រាប់ពួកគាត់ថាខ្ញុំនឹងសរសេរចូលទៅក្នុងរបាយការណ៍ អំពីសំណូមពររបស់ពួកគាត់ ព្រោះអីនៅខេត្តកំពង់ធំយើងនេះមិនទាន់មានគោលការណ៍ដាំកៅស៊ូឱ្យប្រជាពលរដ្ឋនៅឡើយដែរ ហើយកន្លងមកមិនដឹងថាការអភិវឌ្ឍន៍នៅក្នុងស្រុកស្ទោងយើងនេះមានប្រជាពលរដ្ឋចង់ដាំកៅស៊ូ ហើយកាត់ឈូសឆាយដាំឱ្យនៅឡើយទេអត់ដឹង ប៉ុន្តែក្នុងឯកសារនេះគឺខ្ញុំសរសេរអញ្ចឹងរាល់ដីដែលពាក់ព័ន្ធប្រជាជនមិនចង់ធ្វើការដោះដូរ ឬមួយក៏មិនឯកភាពយកការដោះស្រាយតាមគោលការណ៍របស់ក្រុមហ៊ុន ឬតាមតំលៃដែលបានឯកភាពគ្នា អញ្ចឹងសំណូមពរឱ្យក្រុមហ៊ុនឈូសឆាយធ្វើការដាំដុះហើយមានកិច្ចសន្យា ទិញយកនូវផលិតផលដូចករណីដែលក្រុមហ៊ុនធ្លាប់បានអនុវត្តនៅក្នុងតំបន់ឥសានដូចគ្នា ។ ចំណុចដែលសំខាន់នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៅពេលនេះ គឺយើងមើលទៅលើធនធានបរិស្ថាន ហើយយើងមើលទៅលើធនធានសង្គម តើវាអភិវឌ្ឍន៍ទៅកំរិតនៃការប៉ះពាល់នេះអាចដោះស្រាយបានឬមួយយ៉ាង ណានោះជាចំណុចសំខាន់បំផុត ប៉ុន្តែជាក់ស្តែងដោយសារក្រុមហ៊ុននេះជាក្រុមហ៊ុនរបស់វៀតណាម គាត់មានគោលការណ៍ថាមិនធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋទេ ហើយនឹងឈានទៅរកការដាំឱ្យប្រជាជនទៀតផង ។ ដូចនេះកង្វល់ធំរបស់កុងស៊ុលតង់នៅក្នុងបញ្ហានឹង ហើយជាពិសេសថ្នាក់ដឹកនាំខេត្តនិងក្រុមហ៊ុនខ្លួនឯងបានដោះស្រាយរួចអស់ហើយ អំពីបញ្ហារាំងស្ទះមួយចំនួនពេលនេះយើងគ្រាន់តែរង់ចាំមើលពេលដែលដំណើរការអភិវឌ្ឍន៍ទៅនោះ ក្រុមហ៊ុនគាត់អនុវត្តទៅតាមនូវអ្វីដែលក្រុមហ៊ុនបានសន្យាឬអត់ ។ យើងនៅបន្តតាមដានតទៅទៀត ចំណុចចុងក្រោយនេះគឺការស្នើសុំរបស់បងប្អូននៅក្នុងមូលដ្ឋាន (ឃុំពពក ស្រុកស្ទោង) កាលពីថ្ងៃទី ២៩ ខែ ឧសភា ដល់ថ្ងៃទី០៣ មិថុនា ឆ្នាំ ២០១០ ។ បានមានប្រសាសន៍ថា ចំពោះការស្នើសុំដីសម្បទាន ដែលក្រុមហ៊ុនកំពុងអភិវឌ្ឍន៍ប៉ះពាល់ដីស្រែចំការរបស់ប្រជាពលរដ្ឋចំនួនជាង៤០គ្រួសារ ដែលមានស្រែនិងចំការស្វាយចន្ទី តែក្រុមហ៊ុនដោះស្រាយដីស្រែចំការនោះរួចរាល់អស់ហើយ ។ សំណូមពរសុំ

Draft

ឱ្យក្រុមហ៊ុនធ្វើផ្លូវសំរាប់ក្រុមហ៊ុនមួយដោយឡែក ព្រោះសព្វថ្ងៃក្រុមហ៊ុនបើកបរលើផ្លូវដែលជាអំណោយរបស់ ឯកឧត្តម **ងួន ញ៉ិល** ដូចនេះ ហើយរដូវវស្សាអាចខូច បើខូចមិនងាយនឹងមានថវិការជួសជុលវិញទេហើយ នៅតំបន់នេះទើបតែមានផ្លូវស្រួលធ្វើដំណើរទេ ពីមុនមកគឺពិបាកធ្វើដំណើរចេញចូលទៅមកណាស់ ដូចនេះក្រុមហ៊ុនគួរធ្វើផ្លូវមួយដោយឡែកវិញ កុំឱ្យខូចផ្លូវចាស់នេះ ហើយក្រុមហ៊ុនកំឈូសយកឈើទៅ ទំលាក់ក្នុងប្រព័ន្ធអូរធ្វើឱ្យកកស្ទះ និងកខ្វក់ទឹកពិបាកប្រើប្រាស់ និងគោក្របីផឹក។

**មតិយោបល់សរុបរបស់ប្រជាជនដែលបានចូលរួមក្នុងពេលពិគ្រោះយោបល់នៅឃុំសាគ្រាមៈ** ពួកគាត់មិនចង់ឱ្យបានក្រុមហ៊ុនចូលមកអភិវឌ្ឍន៏ទេ ពីព្រោះពួកគាត់ខ្លាចបាត់បង់ដីស្រែចំការ ព្រៃឈើ និងសត្វព្រៃ ហើយនៅពេលដែលក្រុមហ៊ុនចូលមកគេឈូឆាយព្រំដីហ៊ុំព័ទ្ធជិត ដោយជីកប្រឡាយជុំវិញអាច ឱ្យគោក្របីរបស់ពួកគាត់ធ្លាក់មូលស្លាប់បាន។ ជាពិសេសទៅទៀតនោះ កូនចៅគាត់ជំនាន់ក្រោយលែងស្គាល់សត្វ លែងស្គាល់ឈើធ្វើផ្ទះ និងដីចំការស្រែ ដីលំនៅដ្ឋានទៀតហើយ។ តែផ្ទុយទៅវិញ បើក្រុមហ៊ុនគោរពតាម នូវអ្វីដែលពួកគាត់ទាមទារដោយមិនប៉ះពាល់ដល់ដីស្រែចំការ ដើមជ័ររបស់ពួកគាត់នោះ គឺពួកគាត់សុំគាំទ្រនឹងសន្យាចូលរួមយ៉ាងសកម្មធ្វើជាដៃគូជាមួយក្រុមហ៊ុន ក្នុងការអភិវឌ្ឍន៏នៅតំបន់នេះ នឹងធ្វើជាគំរូ បង្ហួតទៅដល់ប្រជាពលរដ្ឋនៅតំបន់ដទៃទៀតឱ្យចូលរួមសហការ ជាមួយក្រុមហ៊ុនដើម្បីជួយអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចំរើនទៅថ្ងៃអនាគត។ ចំណុចនេះខ្ញុំសុំបញ្ជាក់ ថាក្រុមហ៊ុនមិនមានចេតនាប្រើប្រាស់ផ្លូវរបស់សហគមន៏ទេ មានតែជួយអភិវឌ្ឍន៏បន្ថែមទៀតនៅអ្វីដែលខ្វះខាត ដោយសារតែមិនទាន់មានការបូកសរុបនូវកម្មវិធី ដែលក្រុមហ៊ុនចូលរួមអភិវឌ្ឍន៏ក្នុងតំបន់នោះ ដូចជាសាលារៀន មណ្ឌលសុខភាព អណ្តូងទឹកស្អាត ផ្លូវជនបទ យ៉ាងម៉េចនោះ អត់ទាន់អាចជំរាបជូនថ្នាក់ដឹកនាំខេត្តបាននូវពេលនេះទេ ប៉ុន្តែនៅពេលដែលប្រជុំអន្តរក្រសួងនៅ ថ្ងៃទី២៨នេះ នឹងមានការអញ្ជើញថ្នាក់ដឹកនាំខេត្តមួយរូបទៅចូលរួមស្តាប់ថា តើកម្មវិធីចូលរួមអភិវឌ្ឍន៏របស់ ក្រុមហ៊ុននោះមានអ្វីខ្លះ? ដោយឡែខ្ញុំគិតថាអស់លោកថ្នាក់ដឹកនាំស្រុកនឹងអស់លោកអង្គភាពទាំងអស់បាន ជ្រាបហើយដើម្បីអភិវឌ្ឍន៏ទៅជាចំការកៅស៊ូបាននោះ ត្រូវមានផ្លូវខ្វាត់ខ្វែង នៅក្នុងនោះតែម្តងឧទាហរណ៍ ដូចក្រុមហ៊ុនមួយនៅរតនៈគីរីរបស់ឯកឧត្តម គន់ គីម អញ្ជឹងទំហំផ្ទៃដីសរុប១០០០០ហិកតា ឯផ្ទៃដីប្រើប្រាស់បានតែ៧១០០ហិកតា ទេ អញ្ជឹងដើម្បីបង្កលក្ខណៈទ្រទ្រង់ដល់ដំណើរការផលិតកម្មគាត់ត្រូវធ្វើការអភិវឌ្ឍន៏ ផ្លូវសរុប៥០០គ.ម ឯណោះ។ ដូចនេះនៅក្នុងទីតាំងស្រុក ស្មោង និងស្រុកប្រាសាទបាល័ង្ក ឃុំសាគ្រាម អាចចេញចូលមកឃុំពពកបានដោយងាយមិនចាំបាច់ចេញមកផ្លូវជាតិលេខ៦អីនោះទេ។ ក្រុមហ៊ុនត្រូវភ្ជាប់ផ្លូវពីចំការកៅស៊ូមកផ្លូវជាតិ ដើម្បីដឹកនាំផលិតផលរបស់គាត់ចេញចូលជាប្រចាំ ហើយនៅពេលបន្ទាប់នេះខ្ញុំទុកឱកាសឱ្យបង១ដែលជាថ្នាក់ដឹកនាំខេត្តមានមតិយោបល់លើកនូវបញ្ហាផ្សេង១ ដែលនៅមិនទាន់ច្បាស់លាស់ និងធ្វើសំណូមពរអ្វីឱ្យ មានការជឿជាក់ថានៅពេលដែលធ្វើការអភិវឌ្ឍន៏ទៅ ក្រុមហ៊ុនអនុវត្តន៏ទៅតាមអ្វីដែលខ្ញុំធ្វើការអះអាងនៅពេលនេះ ឬយ៉ាងណា។

Draft

**ឯកឧត្តមអភិបាលខេត្ត :** បើតាមរយៈបទបង្ហាញរបស់ក្រុមការងារ ឃើញថាមិនមានប៉ះពាល់អ្វីធំដុំនោះទេ សូមអបអរសាទរ តែខ្ញុំភ័យខ្លាច នៅពេលដែលមានការឈូសឆាយទៅខាងមុខទៀតនោះ មានការប៉ះពាល់ដល់ប្រជាពលរដ្ឋ ដូចនេះដេម្បីបញ្ជាក់ថា ប៉ះពាល់ឬយ៉ាងណានោះសុំឱ្យមានការចូលរួមមតិយោបល់ ពីថ្នាក់ដឹកនាំស្រុកទាំងពីរសិន ហើយចាំខាងជំនាញបច្ចេកទេសមានយោបល់តាមក្រោយ ។

**លោក ហង្ស សុធីម អភិបាលស្រុកស្នោងៈ** សកម្មភាពឈូសឆាយដាំកៅស៊ូនៅស្រុកស្នោងនេះ ជាការពិតទៅការងារបរិស្ថានមិនជាបញ្ហាអ្វីទេ ព្រោះអីមាន **ស.ជ.ណ** ចេញរួចហើយ តែការព្រួយបារម្ភគឺការប៉ះពាល់ទៅលើផលប្រយោជន៍របស់ប្រជាជនយើងខ្ញុំ បើសិនជាការឈូសឆាយទៅប៉ះពាល់ត្រូវធ្វើការដោះស្រាយឱ្យបានសមស្របកន្លងទៅធ្វើការសាកល្បងឈូសឆាយធ្វើផ្លូវ៥គ.ម. ពេលនោះប៉ះពាល់នឹងចំការស្វាយចន្ទីប្រជាពលរដ្ឋក្រុមហ៊ុនក៏បានធ្វើការសំរុះសំរួលដោះស្រាយរួចហើយ ចំពោះដីដែលក្រុមហ៊ុនធ្វើការឈូសឆាយនូវចំនួនផ្ទៃដី ២៥០០ហិកតាឃើញថាមិនមានបញ្ហាកើតឡើងទេ បើតាមគំរោងរបស់ក្រុមហ៊ុននៅពេលខាងមុខនេះ ក្រុមហ៊ុនមានគំរោងឈូសឆាយថែម ២០០០ហិកតា ដោយឡែកចំពោះការប្រើប្រាស់កំលាំងពលកម្មគឺសុទ្ធតែប្រជាជននៅឃុំក្នុងពពកទាំងអស់ ដែលពួកគាត់អាចរកចំណូលបាន១៥០០០រៀលក្នុងមួយថ្ងៃ ហើយក្រុមហ៊ុននៅពេលដែលឈូសទៅប៉ះពាល់ដីចំការស្វាយចន្ទីក្រុមហ៊ុនបានធ្វើការដោះស្រាយផ្ទាល់ ដូចនេះហើយទើបមិនមានបញ្ហាជាមួយប្រជាពលរដ្ឋ។ ប៉ុន្តែបច្ចុប្បន្នអាជ្ញាធរកំពុងមានការព្រួយបារម្ភចំពោះ ប្រជាពលរដ្ឋ នាំគ្នាទៅចាប់យកដីនៅសងខាងផ្លូវដែលក្រុមហ៊ុនធ្វើការឈូសឆាយ ដែលដីនោះជាដីគំរោងស្រុកទុកជាដីសម្បទានសង្គមកិច្ចសំរាប់ប្រជាពលរដ្ឋដែលខ្វះខាតជីពិតប្រាកដ ។

**លោក គឹម អាន អភិបាលស្រុកប្រាសាទបាល័ង្ក :** ថ្ងៃនេះបានចូលរួមស្តាប់ថាមានគំរោង ស្នើសុំដីសម្បទានសេដ្ឋកិច្ច នៅក្នុងភូមិសាស្ត្រស្រុកយើងខ្ញុំ ដែលដីនោះស្ថិតនៅឃុំសាគ្រាម ដែលអាចមានការប៉ះពាល់ច្រើនគឺដីបង្កបង្កើនផល នេះយើងមានការព្រួយបារម្ភ ដូចដែលក្រុមការងារបានរាយការណ៍ហើយថា ប្រជាជននៅតំបន់នោះសុំឱ្យធ្វើការរំកិលចេញចំងាយ៤គ.ម ព្រោះពួកគាត់ព្រួយខ្លាចក្រុមហ៊ុនយកដីរបស់ពួកគាត់ ព្រោះដំណាំរបស់គាត់ដែលដាំទទួលបានផលហើយ បើគេយកដីចំការរបស់គាត់តើគួរធ្វើយ៉ាងម៉េច? តែតាមស្តាប់ការបកស្រាយរបស់ក្រុមការងារធ្វើបងបង្ហាញនៅពេលនេះ ខ្ញុំមានការសប្បាយចិត្ត ព្រោះដីនៅតំបន់នោះតាមការសិក្សា និងការរាយការណ៍ពីមេឃុំគឺមានពាក់ព័ន្ធ និងប្រជាពលរដ្ឋប្រមាណជា៤០០គ្រួសារ ដែលធ្វើចំការនៅទីនោះ ហើយភូមិដែលប៉ះពាល់ធ្ងន់ធ្ងរជាងគេគឺភូមិសាគ្រាមជើង និងភូមិវាលថ្នល់។ ទោះបីកន្លងមកដីដែលពួកគាត់ចូលទៅធ្វើការដាំដុះនោះ និងបង្កបង្កើនផលនោះ ដើមឡើយអាជ្ញាធរធ្វើការហាមឃាត់ការពារខ្លាំងណាស់ ហើយអាជ្ញាធរខ្លួនឯងក៏មិនហ៊ានធ្វើការកាប់រានឈើនៅតំបន់នោះទេ ព្រោះជាដីរបស់ ដែនជំរកហើយបើចង់កាប់ឈើទាល់តែសុំដែនជំរក បើដែនជំរកអនុញ្ញាតទើបអាចកាប់បានសូមរាយការណ៍ជំរាប ឯកឧត្តមដែរថា

Draft

លើកមុនគេបន់ឱ្យតែប្រជាជនចូលទៅកាប់ឱ្យក្លាយទៅជាដីបង្កបង្កើនផលទេ នេះខាងដែនជំរកនេះអ្វីដែលយើងក្តាប់បានអារម្មណ៍អ្នកដែលនៅតំបន់នោះ សូម្បីតែក្រុមប្រឹក្សាឃុំខ្ញុំក៏មានដីនៅទីនោះ៤-៥ហិកតាដែរ ។ ដែលតាមការសំណូមពររបស់ពួកគាត់នៅទីនោះ ទី១សុំឱ្យរំកិលឱ្យឆ្ងាយ៤-៥គ.ម. បើមិនបានទេធ្វើម៉េចដីរបស់គាត់ដែលមានដំណាហើយនោះកុំយករបស់គាត់ អញ្ជឹងសុំឱ្យខាងក្រុមហ៊ុនមានគោលនយោបាយយ៉ាងណាដើម្បីកុំឱ្យមានបញ្ហារវាងក្រុមហ៊ុន និងប្រជាជន ខ្ញុំមានបទពិសោធន៍ហើយរឿងក្រុមហ៊ុនអាកាស្សាចេញជាបាតុកម្មមិនអស់មិនហើយ រហូតដល់ចាប់ប្រជាពលរដ្ឋដាក់ទៅតុលាការ រហូតមកដល់ពេលនេះតុលាការកោះហៅមិនអស់មិនហើយ មិនទាន់ចប់ផងមកដល់ពេលនេះ ។ ចំពោះបញ្ហានេះយើងខ្ញុំជាអាជ្ញាធរក៏មានកង្វល់ដែរ គឺថាប្រជាជននៅទីនោះគឺ គាត់មិនសប្បាយចិត្តតែម្តង គឺវាពាក់ព័ន្ធនឹងសតិអារម្មណ៍របស់ពួកគាត់ ហើយនៅកន្លែងខ្លះគាត់មិនពេញចិត្ត គេនិយាយថាមិនបោះឆ្នោតឱ្យតែម្តង ខ្ញុំបានអញ្ជើញធ្វើការជាមួយឃុំ និងក្រុមប្រឹក្សាឃុំមកនិយាយគ្នាម្តងហើយប្រាប់ថានេះជា**ស.ជ.ណ.** ដែលជាសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ដូចនេះខ្ញុំជាតំណាងមន្ត្រីរាជរដ្ឋាភិបាល ត្រូវតែការពារច្បាប់របស់រាជរដ្ឋាភិបាលមិនអាចឱ្យលប់**ស.ជ.ណ.**របស់រាជរដ្ឋាភិបាលដោយសារតែប្រជាជននៅតំបន់នោះទេ តែខ្ញុំសំណូមពរចំពោះឯកឧត្តមឬតំណាងក្រុមហ៊ុន បើសិនជាយើងរួមគ្នាអនុវត្តន៏ **ស.ជ.ណ.** សុំធ្វើការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ បិទប្រកាសឱ្យប្រជាពលរដ្ឋឱ្យបានទូលំទូលាយថាតើត្រូវដោះស្រាយយ៉ាងម៉េច? តែខ្ញុំបានបញ្ជាក់ប្រាប់បងប្អូនប្រជាពលរដ្ឋហើយថា យើងប្រគល់ដីព្រៃទាំងនោះឱ្យទៅក្រុមហ៊ុនធ្វើការអភិវឌ្ឍន៏ ហើយយើងធ្វើការងារជាមួយក្រុមហ៊ុននោះវាទទួល បានចំណូលជាប់លាប់ពិសេសជៀសវាងចេញទៅរកការងារធ្វើនៅខាងក្រៅ ។ ហើយកន្លងមកគេចោទថា ក្រុមប្រឹក្សាឃុំរួមទាំងចៅហ្វាយស្រុកទទួលបានលុយ១៥ម៉ឺនដុល្លចែកគ្នា ប៉ុន្តែខ្ញុំសួរថាអ្នកណានិយាយស្រង់ឈ្មោះមក ឥឡូវខ្ញុំឱ្យគេធ្វើពាក្យបណ្តឹងពីពួកអ្នកដែលនិយាយបំផ្លើសការពិតទាំងនោះហើយ ការធ្វើយ៉ាងនេះកុំឱ្យពួកគាត់ចេះតែនិយាយផ្តេសផ្តាស់ទៀត ។ តែខ្ញុំសូមអបអរសាទរដែលបានក្រុមហ៊ុនចូលមកអភិវឌ្ឍន៏នៅតំបន់នេះណាស់ តែសុំកុំធ្វើដូចក្រុមហ៊ុនដាំអាកាស្យមុននោះអី គឺកន្លងមកអាជ្ញធរមានការឈឺក្បាលណាស់ចំពោះក្រុមហ៊ុនដាំអាកាស្សានោះ ។

**លោក ហេង ប៊ុនធឿន អនុប្រធានមន្ទីរបរិស្ថានៈ** សូមគោរពឯកឧត្តនប្រធានអង្គប្រជុំ និងបង១ទាំងអស់ ក្រោយពីបានស្តាប់របាយការណ៍វាតតំលៃរបស់ក្រុមការងារបច្ចេកទេសរួចមក ខ្ញុំសង្កេតឃើញថាក្រុមការងារមិនបាននិយាយអំពីរឿងពាក់ព័ន្ធ និងអូរ បឹង តាមមាត់ប្រភពទឹកទាំងនោះ ដែលតាមគោលការណ៍របស់បរិស្ថានគឺត្រូវរក្សាព្រៃនៅតាមសងខាងអូរ ដើម្បីការពារទីជំរាល ឬការហូរច្រោះ ថាតើត្រូវរក្សាទុករបៈចំងាយប៉ុន្មានម៉ែតពីមាត់អូរព្រែកស្ទឹង? តាមច្បាប់របស់បរិស្ថានត្រូវរក្សាទុកចំងាយ១០០-២០០ម៉ែត្រ ។ មានរឿងមួយខ្ញុំបានទៅពពកដើម្បីធ្វើការផ្សព្វផ្សាយអំពីការយល់ដឹងពីបរិស្ថាន ដែលអញ្ជើញប្រជាជនចូលរួមជាគោលការណ៍១០០នាក់ តែមេឃុំគាត់ចង់ឱ្យប្រជាជនចូលរួមស្តាប់ឱ្យបានច្រើនគាត់អញ្ជើញប្រជាជនចូលរួមរហូតដល់ជាង២០០នាក់ ។ ពេលនោះគាត់សួរខ្ញុំទាក់ទងនឹងការឈូសឆាយព្រៃមាត់នៅបឹង តើបរិស្ថាគិតគូរយ៉ាងម៉េចដែរ? ហើយខ្ញុំបានឆ្លើយទៅគាត់

Draft

ភ្លាមថា ជាគោលកាណ៍គេមិនឱ្យឈូសទេនៅតាមមាត់បឹង អូរក៏អញ្ចឹងដែរ ស្ទឹង ត្រពាំង គេទុក១០០-២០០ម. ជុំវិញជាតំបន់ទ្រនាប់ នេះជាកោលការណ៍របស់បរិស្ថាន ចំពោះក្រុមហ៊ុននេះខ្ញុំមិនដឹងច្បាស់ទេព្រៃនៅតំបន់ជំរកសត្វនេះ ក្រែងលោមានករណីពិសេសរបស់រដ្ឋាភិបាល ឬយ៉ាងម៉េច បានឈូសអស់មិនទុកព្រៃទ្រនាប់ទាំងនោះសោះ ។ តែខ្ញុំសុំសួរទៅខាងក្រុមអ្នកសិក្សាដែរថា តើបានដឹងឬអត់ទេ ដែលក្រុមហ៊ុនឈូស (បឹង ឡប )ហើយជាសំណូមពររបស់ប្រជាពលរដ្ឋ គាត់ថាគួរតែទុកព្រៃមាត់បឹងនោះ ។ នេះពាក់ព័ន្ធនឹងបរិស្ថាន តែខ្ញុំមិនដឹងទៀតដែរថាវានៅមាន ពាក់ព័ន្ធនឹងព្រៃអ្នកតាអីទៀតនោះទេ បើមានគួរតែទុកដែរ ។ ទាក់ទងនិងការវាយតំលៃផ្នែកសង្គមនេះ ខាងស្រុក គាត់បានមានយោបល់រួចហើយ ហើយខ្ញុំក៏មិនបានចុះផ្ទាល់ដែរ សូមអធ្យាស្រ័សូមចប់សូមអគុណ ។

**បណ្ឌិត លី សុពណ៌-មុនីៈ** ខ្ញុំសូមបញ្ជាក់បន្តិចទៅលើអ្វីខាងមន្ទីរបរិស្ថានបានលើកជាក់ស្តែងខ្ញុំមានការងើងឆ្ងល់ដែរធម្មតាដីសម្បទានសេដ្ឋកិច្ចគឺ ធ្វើនៅក្នុងក្របខ័ណ្ឌក្រសួងកសិកម្ម នៅក្នុងក្រសួងសិកម្មនៅពេលដែលគាត់ផ្តល់ផែនទីមកគឺគាត់កាត់ចេញហើយស្រេច ជាក់ស្តែងដូចដី ស៊ី អ ស៊ី ខេ ២ ៧ពាន់ប៉ុន្មានរយហិកតានោះឃើញកាត់ដែរគឺកាត់តែអូរនេះមួយទេបានន័យថាតំបន់ទ្រនាប់១០០-២០០ម៉ែត្រនេះគឺកាត់សងខាង ប៉ុន្តែអូរ( អូរគោលង់) នេះវិញមិនមានជើញកាត់ចេញដែរ ដោយឡែកទៀតផែនការមេពឹងខាងក្រសួងកសិកម្មឱ្យធ្វើ អញ្ចឹងមិនដឹងថា គេបានកាត់ហើយនៅទេ ខ្ញុំលើកឧទាហរណ៍ ដីជំរកសត្វរបស់ក្រសួងបរិស្ថានដែរ បានផ្តល់ឱ្យទៅក្រុមហ៊ុន អេច.អិល.អេច. ដែលក្រុមហ៊ុននេះជំទាវ ហ៊ុន សេងនី ប្អូនស្រីរបស់សម្តេច នោះគាត់បានទាក់ទាញក្រុមហ៊ុននេះ មកអភិវឌ្ឍន៍ពោតនៅតំបន់នោះ ដីនោះមួយម៉ឺនហិកតាជាងដល់ពេលក្រសួងបរិស្ថានកាត់ឱ្យទៅដល់ពេលក្រុមហ៊ុនបានទៅពឹងកសិកម្ម ហើយដល់ពេលក្រសួងកសិម្មអាងថាក្រសួងបរិស្ថានផ្តល់ឱ្យហើយ ព្រៃស្រោងនឹងពាក់កណ្តាលស្រោងអត់កាត់ចេញ ដល់ពេលខ្ញុំធ្វើការសរសេរ អីអាយអេដាក់ទៅការពារមានជាប់ឯណា ដល់ពេលកំហុសមិនមែនកំហុសអ្នកសរសេរឯណា ជាកំហុសអ្នកសរសេរផែនការមេ ព្រោះអី EIA ធ្វើតាមផែនការមេទេ អញ្ចឹងអំទេសរដ្ឋមន្ត្រីទាមទារឱ្យខ្ញុំកែរផែនការមេឡើងវិញ ព្រោះអីតំបន់នោះគាត់ចង់អញ្ជើញសម្តេចទៅសម្ពោធនៅកន្លែងនោះអញ្ចឹងជាក់ស្តែងនៅក្នុងបញ្ហានេះ បងប្រធានមន្ទីរកុំបារម្ភណ៍ នៅប្រជុំអន្តរក្រសួងនឹងលើកឡើង ជាទូទៅនូវអ្វីដែលពាក់ព័ន្ធគឺលើកឡើង ជាទូទៅផ្ទៃដីសំរាប់ប្រើប្រាស់តាមលក្ខណៈបរិស្ថាន និងសង្គមបានក្រុមហ៊ុនគេទទួលយក ។ នៅក្នុង **សជណ** ដូចពូអភិបាលស្រុកស្មោងលើកឡើងហើយ ផ្តល់ឱ្យតែនៅអ្វីដែលពាក់ព័ន្ធគឺកាត់ចេញ ។

**ឯកឧត្តម អ៊ុក សំអង អភិបាលរងខេត្ត :** ក្រោយពីស្តាប់ការបកស្រាយ នឹងសេចក្តីរាយការពីលោកតំណាងក្រុមហ៊ុន និងលោកអភិបាលស្រុកទាំងពីរមក ឃើញថា មិនមានប៉ះពាល់អីធំដុំទេ ព្រោះសជណបានចេញរួចហើយ ដូចនេះយើងត្រូវរួមគ្នាដោះស្រាយ(១)ដោះស្រាយជាលុយកាក់ (២)បើសិនជាមានគំរោងទៀតនោះគឺការបង្វែរពីការដាំស្រូវនឹងដំនាំផ្សេងៗរបស់គាត់មកជាការដាំកៅស៊ូ ។ល ។ ហើយនៅត្រង់ថាការស្នើសុំពីប្រជាជនថាឱ្យក្រុមហ៊ុនរំកិលទីតាំងនោះបើធ្វើមិនបានតើគួរធ្វើយ៉ាងម៉េច? នេះជាឆ័ន្ទៈគាត់មិនចង់ឱ្យដីនោះទៅក្រុមហ៊ុន ដែល

Draft

ស្ថិតនៅ ក្នុងវង្វង់សជណដែលបានចេញ ហើយ(៣)គាត់បារម្ភណ៍ខលាចគេយកដីរបស់គាត់នេះសុទ្ធតែជាឆ័ន្ទៈរបស់ពួកគាត់ ព្រោះកាត់ប្រកាន់ថាដីនេះជាដីរបស់គាត់ ចុះបើក្រុមហ៊ុនធ្វើការឈូសឆាយទៅពាក់ព័ន្ធនឹងដីរបស់ប្រជាពលរដ្ឋត្រូវសហការរួមគ្នធ្វើការដោះស្រាយ បើគាត់លក់ក្រុមហ៊ុនប្រមូលទិញទៅ បើកាត់មិនលក់ក្រុមហ៊ុនឆ្វៀលចេញទៅចំពោះ ហើយកន្លងមកយើងសុំសសើរដែរពីការទន់ភ្លន់របស់ក្រុមហ៊ុនតាន់បៀន របស់កៅស៊ូវៀតណាម។ គឺគាត់្បមានគោលនយោបាយដូចកាត់លើកឡើងអញ្ចឹងកាលពីថ្ងៃសៅខ្ញុំបានចុះទៅជួបអំពីការដោះស្រាយសេសសល់បន្ត កាត់ធ្វើប៉ះត្រង់ណាដែលមានចំការគឺគាត់ក្រឡឹងសិន ហើយកាត់ស្រាវជ្រាវរកម្ចាស់ដោយខ្លួនឯងគត់ចរចារជាទ្វេរភាគី តែបើកាត់ចរចារបាននោះយើងមិនមានការឈឺក្បាលទេ តែដែលខ្ញុំចុះទៅនេះគឺបញ្ហាសេសសល់ដី៤០ហិកតា និង១២គ្រួសារ តាមពិតទំហំមានគោលនយោបាយដូចគ្នអញ្ចឹង តែដោយពួកគាត់មានការរឹងត្អឹងដូចនេះគាត់ថាអត់ដីធ្វើចំការ ហើយការដោះស្រាយគោលនយោបាយគាត់អត់និយាយឱ្យចំ ធ្វើឱ្យក្រុមហ៊ុនទាល់ដូចនេះលែងធ្វើពីរភាគី ក៏ពឹងសមត្ថកិច្ចធ្វើការចរចារពភាគីម្តង។ ដូចនេះគំរូវឱ្យមានអ្នកសម្របសម្រួល ឃើញថាមានប្រសិទ្ធិភាពដែរ តែមិនទាន់មានជោគជ័យ១០០%ទេ តែសមត្ថកិច្ចយើងបានលើកយកច្បាប់ មកនិយាយទៅគាត់ ពេលនោះគាត់អាចទទួលយកបាន គាត់សុខចិត្តបោះបង់ដីតែគាត់ទាមទារយកតំលៃខ្ពស់ តែក្រុមហ៊ុនមានតំលៃស្តង់ដាមួយ។ ទោះបីមានការចេញសជណប្រគល់ដីនេះឱ្យក្រុមហ៊ុនមែន តែ**សជណ** មានភ្លើងខៀវឱ្យដោះស្រាយគោលនយោបាយដោះដូរក្នុងករណីចាំបាច់។ ដូចនេះយើងវាយតំលៃថាតើប្រជាជនកាន់កាប់ដីនោះស្របច្បាប់ឬមិនស្របច្បាប់យើងអាចដឹងថាដីរបស់ពួកគាត់នោះគឺមិនស្របទេ ដោយសារតែដីតំបន់នោះជាដីសាធារណៈរបស់រដ្ឋតែសភាពជាក់ស្តែងគាត់ប្រកាន់យកថាដីនោះជាដីរបស់គាត់ ដូចនេះយើងមានគោលនយោបាយពីរ មួយបើគាត់ស្រុះស្រួលជាមួយយើងបានន័យថាទទួលគាត់ទទួលយក បើគាត់មិនស្រុះស្រួលទេ យើងធ្វើបន្តទៀតគឺ បន្តការចរចារទៀត ហើយចុងក្រោយយើងធ្វើការអនុវត្តតាមផ្លូវច្បាប់ ដូចនេះចំពោះដីនៅស្រុកពីរនេះ ឃើញថាស្រុកស្នោងមិនមានបញ្ហាអ្វីជាធំដុំទេ តែស្រុកប្រាសាទបាល័ង្កមានពាក់ព័ន្ធដល់ទៅ៤០០គ្រួសារ ដូចនេះឃើញថាវាមានសភាពធ្ងន់ធ្ងរដែលយើងត្រូវរង់ចាំរួមគ្នាធ្វើការដោះស្រាយឱ្យទទួលបានជេគជ័យដោយគោលការណ៍របស់ក្រុមហ៊ុនធ្វើការដោះ ការដោះស្រាយនេះបើប្រជាជនមិនយល់ព្រម(១) ត្រូវធ្វើកាតកាត់ចេញដីនោះទុកឱ្យគាត់ (២)បើគាត់ព្រមលក់ដីនោះឱ្យក្រុមហ៊ុន រកុមហ៊ុនទទួលទិញយកដីនោះ (៣) គោលការណ៍ដំណោះស្រាយដាំកៅស៊ូឱ្យ ប្រជាជននោះ យើងមិនទាន់ឃើញក្រុមហ៊ុនអនុវត្តនៅឡើយទេ។ ដូចនេះសុំឱ្យក្រុមការ ងារលោកមុនីធ្វើការបកស្រាយបន្ថែមឱ្យចំគោលដៅ ដើម្បីរួមគ្នាដោះស្រាយ។

**ឯកឧត្តមអភិបាលខេត្ត :** មុននឹងផ្ទេរឱ្យក្រុមការងារធ្វើការបកស្រាយ និងមានយោបល់បន្ត ខ្ញុំសុំធ្វើការបញ្ជាក់និងសំណួរអ្វី១ទាំងអស់ដែលក្រុមហ៊ុនធ្វើដំណើរទៅតាមផ្លូវច្បាប់ដែលបានអនុញ្ញាតហើយនោះ ជានិច្ចកាលក្រុមហ៊ុនមិនអាចធ្វើការម្នាក់ឯងបានទេ ហើយបើក្រុមហ៊ុនហានធ្វើម្នាក់ឯងក្រុមហ៊ុនត្រូវហ៊ានទទួលខុសត្រូវម្នាក់ឯងដូចនេះសុំសួរថា តើការបើកការដ្ឋានឈូសឆាយនេះបានបើកជាផ្លូវការឬហើយឬនៅទេ? ព្រោះអាជ្ញាធរខេត្តអត់



Draft

ដឹងថាគេបើកការដ្ឋានឈូសឆាយទេ (២) ខ្ញុំឃើញក្រុមហ៊ុន C.R.C.K.2 ឈូសបាន២៤០០ហិកតា ហើយ តើក្រុមហ៊ុនមួយទៀតឈូសបានប៉ុន្មានហិកតាដែរ? (៣)៤០០គ្រួសារដែលមានដីពាក់ព័ន្ធនៅឃុំសាគ្រាមនោះ តើក្រុមហ៊ុនទទួលស្គាល់ពីហេតុប៉ះពាល់ទេ? សុំធ្វើការបញ្ជាក់ នឹងបំភ្លឺបញ្ហានេះ ។

**បណ្ឌិត លី សុពណ៌-មុនី:** ខ្ញុំសុំបំភ្លឺសំណួរឯកឧត្តមនូវសំណួរទី១ តើការដ្ឋាននោះស្នើសុំបើកជាផ្លូវការហើយយ៉ាងណា? ខ្ញុំមិនបានដឹងថាការបើកការដ្ឋានោះ ក្រុមហ៊ុនបានចំលងជូនមកខេត្តហើយឬយ៉ាងណានោះទេ ប៉ុន្តែជាគោលការណ៍នៅប្រទេសដទៃទៀត មុនដែលក្រសួងបរិស្ថានចេញជាគោលការណ៍ក្រុមហ៊ុនមិនអាចធ្វើអ្វីបានទាំងអស់ ប៉ុន្តែក្នុងករណីប្រទេសកម្ពុជា តែងមានការអនុគ្រោះ កាលមុនអត់ទាំងមានធ្វើ EIA ផងសុំជុំពាក់សិនចាំពេលវេលាសមស្របណាមួយចាំបំពេញជាក្រោយ ប៉ុន្តែបច្ចុប្បន្ននេះ ក៏នៅមានការអនុគ្រោះឱ្យធ្វើការអភិវឌ្ឍន៍សិនចាំធ្វើការវាយតំលៃជាបណ្តើរៗ ប៉ុន្តែរឿងករណីឈូសឆាយទោះបីជាក្រុមហ៊ុនទទួលបានសជណហើយក្តី ក្រុមហ៊ុនមិនអាចធ្វើការឈូសឆាយដោយគ្មានការសំរេចពីក្រសួងបរិស្ថាននោះទេ ជាក់ស្តែងក្រុមហ៊ុនទាំងពីនោះបានធ្វើការស្នើសុំទៅក្រសួងបរិស្ថានរួចហើយ គ្រាន់តែការស្នើសុំនោះ ក្រុមហ៊ុនគេមិនបានចំលងជូនមកខេត្តហើយ ក្រសួងបរិស្ថានបានចំលងជូនមកថ្នាក់ដឹកនាំខេត្តឬ មិនបានយ៉ាងណា ខ្ញុំមិនបានដឹងទេទាល់តែខ្ញុំទាក់ទងទៅខាងក្រុមហ៊ុនទើបអាចបញ្ជាក់ប្រាប់ឯកឧត្តមបាន ។ ចំណែកទី(២) ចំពោះក្រុមហ៊ុន CRCK2 ឈូសបាន២៤០០ហិកតា ហើយក្រុមហ៊ុនបៀនហៀកមកដល់ពេលនេះគឺមិនទាន់ធ្វើការឈូសទេ ព្រោះការងារនេះលឿនមែនទែនគោលការណ៍នេះ បើខ្ញុំចាំបានទើបកន្លះឆ្នាំគត់ដែលឈូសជំហានដំបូងនេះធ្វើនៅCRCK2 មូលហេតុនេះព្រោះមធ្យោបាយចេញចូលងាយជាងខាងក្រុមហ៊ុន **បៀន ហៀក** ដូច្នេះហើយទើបក្រុមហ៊ុន CRCK2 ចាប់ផ្តើមមុន ចំណែកបៀនហៀក ដូចឯកឧត្តមជ្រាបស្រាប់ហើយចេញពីសាលាវិស័យទៅ៥៨គម. ហើយចេញពីសាគ្រាមទៀតប្រហែលជា៣គ.ម ប៉ុន្តែមិនយូរទេព្រោះក្រុមហ៊ុនវៀតណាមមិនថាដីប៉ុន្មានទេគឺចង់ដាំតែ៣ឆ្នាំឱ្យហើយ ក្រុមហ៊ុនមិនមានចេតនាពន្យាពេលអនុវត្តគំរោងដូចក្រុមហ៊ុនដទៃទៀតទេ ជាទូទៅឱ្យតែគំរោងធំៗក្រសួងតែងតែរុញមកឱ្យខាងយើងខ្ញុំធ្វើការវាយតំលៃ ដោយសារការវាយតំលៃរបស់ក្រុមការងារយើងខ្ញុំនឹងគឺមានលក្ខណៈសុក្រិត្យមានលក្ខណៈស្តង់ដាបច្ចេកទេស របាយការណ៍យើងខ្ញុំបានដាក់ចូលដល់ក្រសួងការបរទេសបារាំងអីជាដើម ។ បានជាខ្ញុំដឹងច្រើន ពីព្រោះដីសម្បទាន១០០ក្រុមហ៊ុន ខ្ញុំក្រុមការងារយើងទទួលធ្វើ៨០% ហើយចំពោះក្រុមហ៊ុនវៀតណាមវិញ ក្រោយទទួលបានដីហើយគឺអនុវត្តន៍គំរោងភ្លាមតែម្តង ខុសពីក្រុមហ៊ុនដទៃទៀតក្រោយទទួលបានដីហើយច្រើនតែរង់ចាំរកក្រុមហ៊ុនផ្ទេរបន្តដើម្បីយកកំរៃ ។ ដូចនេះក្រុមហ៊ុនទាំងពីនេះអាចធ្វើការដាំដុះ ក្នុងរង្វង់ក្នុងកំឡុងខែ៥ ឆ្នាំ២០១២យ៉ាងយូរ ។ ចំណែកឯសំណួរទី៣ ក្រុមកាងារយើងបានចុះទៅឃុំសាគ្រាមនេះ យើងបានចុះទៅជួបជាមួយប្រជាពលរដ្ឋ ចំនួន១៧៥នាក់ ហើយនៅពេលដែលខ្ញុំចូលទៅក្នុងព្រៃក៏បានជួបជាមួយនឹងបងប្អូនដាក់អង្គរម្នាក់១៥កំប៉ុង ថាចូលទៅរើសជ័រចុង ហើយខ្ញុំក៏បាន

បញ្ចូលមនោគមន៍ទៅពួកគាត់ថា ដោយសួរថាការរកជ័រចុងនេះអាចរកកំរៃបានប៉ុន្មាន និងនិយាយអំពីថាមានក្រុមហ៊ុនអីមកវិនិយោគអញ្ចឹង ហើយគាត់បានលើកសំណួមពរ ឱ្យរំកិលអីដូចខាងបងអភិបាលស្រុកមានប្រសាសន៍អញ្ចឹង ហើយរំកិលមិនមែនជាវិធីសាស្ត្រមួយទេ ព្រោះត្រូវធ្វើការកែលើ**សជណ**អីទៀតកន្លងមកគឺអត់តែម្តង បើដោះស្រាយមិនចេញក្រុមហ៊ុនធ្វើតាមផ្ទៃដីជាក់ស្តែងហើយអ្វីដែលជាខ្ញុំ និយាយជាការពិតនូវអ្វីដែលពួកគាត់បារម្ភណ៍។ ក្រុមហ៊ុនមិនទាន់បានចុះទៅដល់ទេ តែសហការីខ្ញុំបានទៅចុះទៅក៏បានលើកឡើងបញ្ហានេះ ហើយខ្ញុំបានប្រាប់ទៅពួកគាត់ថាកុំភ័យខ្ញុំនឹងសរសេរ ចូលទៅក្នុងរបាយការណ៍ដាក់ថាករណីដីដែលបងប្អូនមិនទទួលការដោះដូរនោះ សុំឱ្យក្រុមហ៊ុនឈូសឆាយ ហើយដាំឱ្យពួគាត់និងធ្វើការលើកអំពីតំលៃសេដ្ឋកិច្ច លើកតាំងពីកំលាំងពលកម្មឡើង បច្ចុប្បន្នឆ្នាំ២០១០ បើយើងមើល ពីឆ្នាំ២០០០ស្ថានភាពធនធានព្រៃនៅតំបន់នោះយ៉ាងម៉េច? ចូលក្រោយភូមិបន្តិចទៅគឺមានឈើកាប់ហើយ ហើយបើ២០ឆ្នាំមុនឈ្លូសប្រើសអីចូលមកដល់ផ្ទះរបស់គាត់ទៀតផងងាកទៅត្រង់នាក៏សត្វងាកទៅត្រង់ណាក៏សុទ្ធតែធនធានធម្មជាតិ ប៉ុន្តែ២០ឆ្នាំក្រោយធានធានកាន់តែរេចរិលទៅៗ ចុះ១០ឆ្នាំក្រោយ យើងអាចទៅឆ្ងាយពីភូមិច្រើនគីឡូទៀតទើមរកអុសបាន ហើយ២០ឆ្នាំក្រោយអុសក៏ពិបាកនឹងរកដែរ ហើយនិយាយពីការធ្វើស្រែចំការនៅក្នុងតំបន់នឹងមួយហិកតាពិបាកបានផងពីរតោន ហើយដេម្បីធ្វើស្រូវមួយហិកតាមនុស្សក្នុងគ្រួសារគឺរវល់ទាំងអស់ នៅក្នុងរដូវបង្កបង្កើនផល យើងសាបព្រោះខ្លួនឯងតែដល់ ពេលយើងប្រវាសដៃ ដល់ពេលស្ទូងកយើងប្រវាស់ដៃឬក៏ជួលទៅច្រូតក៏អញ្ចឹង បើមើលតាមលក្ខណៈសេដ្ឋកិច្ច ប្រជាពលរដ្ឋទាំងអស់ធ្វើការគឺខាតជារៀងរាល់ឆ្នាំ តែដោយសារគាត់អត់មានជំរើស ហើយពលកម្មនៅក្នុងគ្រួសាររបស់គាត់អត់គិតថ្លៃ ដូចនេះគាត់ចេះតែធ្វើៗទៅបន្តប្រពៃណីទំនៀមទំលាប់គាត់ដែលមានពីដូនតាមក គឺដោយ សារតែគាត់គ្មានជំរើស ប៉ុន្តែនៅពេលដែលមានក្រុមហ៊ុនចូលទៅអ្វីដែលជាផលប្រយោជន៏របស់គាត់ទីមួយគឺ បង្កលក្ខណៈឱកាសនៃការស្រូបយកកំលាំងពលកម្មទី២គឺធ្វើឱ្យមានចរន្តសេដ្ឋកិច្ច យ៉ាងហោច១ម៉ឺនហិកតា ក៏មាន មនុស្សធ្វើការជាប្រចាំ៣០០០នាក់ដែរ ដូចនេះមនុស្សទាំងនោះត្រូវការស្បៀង និងប្រើប្រាស់ប្រព័ន្ធសេវាកម្មផ្សេងៗ អញ្ចឹងធ្វើឱ្យចរន្ធសេដ្ឋកិច្ចនៅក្នុងតំបន់មានការលូតលាស់ នៅក្នុងចំការកៅស៊ូគិតក្នុងកំរៃពលកម្ម ដោយសារកៅស៊ូ វាមានរដូវវាដែរ នៅពេលកៅស៊ូជ្រុះស្លឹកផ្អាកក្នុងរង្វង់១ខែកន្លះឬ២ខែ ប៉ុន្តែកំរៃពលកម្មមធ្យមគឺ១០០ដុល្លា ហើយបើគ្រួសារ២នាក់ទៅធ្វើការនៅក្នុងនឹងមួយឆាំកាត់បាន២៤០០ដុល្លា ដូចនេះពេលនាក់ដោយក៏គាត់មិនអាចធ្វើការបាន២៤០០ដុល្លាដែរ លើកលែងតែមានគ្រួសារមយយចំនួនដែលគាត់មានលទ្ធភាពចូលទៅកាប់ព្រៃឈើ ដែលសកម្មភាពនោះវាប្រាស់ចាកនឹងច្បាប់របស់រដ្ឋ អញ្ចឹងហើយខ្ញុំបានប្រាប់ទៅពួកគាត់គួរកប្រភពកំលាំងពលកម្មមួយ ដែលមានលក្ខណៈឋិតថេរ ទោះបីចូលព្រៃវាបានមែនតែមួយរយៈ ដូចនេះកាត់យល់ពួកគាត់មានការសប្បាយចិត្ត គោលការណ៍យើងអាចដោះស្រាយតាមផ្លូវនោះពិតប្រាកដមែន យើងនៅចាំមើលព្រោះក្រុមហ៊ុននេះ ជាក្រុម ហ៊ុនគ្រប់គ្រងដោយរដ្ឋគេមិនធ្វើអ្វីឱ្យប៉ះពាល់ដលប្រជាពលរដ្ឋទេ។

Draft

**ឯកឧត្តមអភិបាលខេត្ត** : ឥឡូវនេះខ្ញុំយោងតាមរបាយការណ៍ និងការវិភាគយោបល់ពីមូលដ្ឋានមកខ្ញុំអាចកត់សំគាល់បានថាដំណើរការរបស់ក្រុមហ៊ុនមានភាពរលូនច្រើន នេះសំរាប់ក្រុមហ៊ុន C.R.K.2 ដែលអាចឱ្យយើងទទួលយកបាន។ ប៉ុន្តែវាបន្សល់ទុកនូវបញ្ហាដែលយើងត្រូវដោះស្រាយជាមួយនឹងប្រជាពលរដ្ឋនៅតំបន់នោះជាតំបន់ដែលប្រជាជនចំរុះមានជនជាតិតិចផង ជនជាតិច្រើនផង ហើយការចេះដឹងក្នុងកំរិត។ ហើយតំបន់នោះពីមុនមកជាតំបន់ដែលមិនមែនស្ថិតនៅក្នុងការគ្រប់គ្រងរបស់ភាគីកម្ពុជានោះទេ វាជាតំបន់គ្រប់គ្រងដោយភាគីដែលប្រយុទ្ធប្រឆាំងជាមួយនឹងភាគីរដ្ឋកម្ពុជា ដូចនេះអារម្មណ៍របស់ពួកគាត់មិនទាន់មានការជ្រះស្រឡះទាំងស្រុងនៅឡើយដែរទេ ប្រសិនបើមានការចាក់ចុចពីភាគីណាមួយនោះ ដូចនេះក្រុមហ៊ុនត្រូវប្រុងប្រយ័ត្នក្នុងការងារ របស់ខ្លួនដើម្បីសុវត្ថភាព និងនិរន្តរភាព ជាវិធានការទៅមុខក្រុមហ៊ុនត្រូវគិតអំពីផ្លូវចូល ប្រសិនបើក្រុមហ៊ុនធ្វើការប្រើប្រាស់ច្រើនផ្លូវនោះគឺវាអត់ធានាទេអាចខូចផ្លូវ ហើយនឹងហុយធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋតំបន់នោះ។ ការនិយាយពីផ្លូវនេះ គឺគិតពីផ្លូវខាងក្រៅទេ គឺគិតពីផ្លូវជាតិចូលទៅក្រុមហ៊ុនក្រុមហ៊ុនរបស់លោក ឬពីផ្លូវលេខ៦២ទៅតំបន់របស់លោក ក្រុមហ៊ុនត្រូវជួសជុលផ្លូវដែលមានហើយ ក្រុមហ៊ុនត្រូវធ្វើផ្លូវដែលមិនឋិតនៅក្នុង រង្វង់ក្រុមហ៊ុន (ផ្លូវក្រៅក្រុមហ៊ុន) ដើម្បីជួយកែលំអរ។ ដូច្នេះទាក់ទងជាមួយបញ្ហានេះក្រុមហ៊ុនត្រូវគិតអំពីការជួយស្ដារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាអណ្ដូងទឹក ផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព ដែលប្រជាពលរដ្ឋចង់បាន និងសំណូមពរដើម្បីស្ដារអរូបវន្ត (ផ្លូវចិត្ត) ឱ្យកាត់ហ្នឹងហ្នំ បើតាមការចុះទៅតំបន់នោះ២ដងហើយនៅខ្វះខាត សាលារៀន ផ្លូវ អណ្ដូងទឹក ប៉ុស្តិ៍សុខភាព ហើយតំបន់នោះមាខាងក្រសួង ខាងមន្ទីររៀបចំតំបន់សហគមន៍ព្រៃឈើ ដោយសារការអភិវឌ្ឍន៍នៅមានកំរិតគាត់នៅប្រើប្រាស់ឈើជាមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគាត់។ បើនិយាយឱ្យច្បាស់ទៅគឺថាសុំឱ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តឬក៏ជួយអ្វីក្រៅពីនោះទៀត ក្នុងនោះខ្ញុំគិតថាក្រុមហ៊ុនអាចធ្វើបាននេះមិនបង្ខំទេតែក៏មិនឱ្យបដិសេធនឹងដែរ ។(២) ក្រុមហ៊ុនត្រូវសហការជាមួយ អាជ្ញាធរមូលដ្ឋាន នឹងជំនាញពាក់លព័ន្ធ ដើម្បីដោះស្រាយរួមគ្នា ដោះស្រាយឱ្យអស់នូវហេតុផលប៉ះពាល់ ជាមួយ ប្រជាពលរដ្ឋបើមានត្រូវដោះឱ្យអស់។ ហើយម្យ៉ាងទៀតពេលក្រុមហ៊ុនឈូសឆាយពេលមានការតវ៉ាពីប្រជាពលរដ្ឋ ត្រូវបញ្ឈប់សកម្មភាពភ្លាមបង្វែរទៅគោលដៅផ្សេងទុកចំណុចនោះដោះស្រាយ អោយស្រុកសហការណ៍ ជាមួយ ក្រុមហ៊ុនឱ្យបានល្អ ជៀសវាងជំលោះកើតមានឡើងតាមរូបភាពណាមួយ (៣) រួមគ្នាដោះស្រាយបញ្ហាបរិស្ថាន បញ្ចៀសការឈូសឆាយអូរ បឹង ស្ទឹង បើមាន ដើម្បីថែរក្សាធនធានធម្មជាតិ តាមដងអូរ និងការពារការហូរ ច្រោះដីបណ្ដាលពីការឈូសឆាយរបស់ក្រុមហ៊ុន ព្រោះបើគ្មានការទប់ស្កាត់ទេអាចបណ្ដាលឱ្យមានផលវិបាកទៅ ថ្ងៃណាមួយដែលយើងមិនអាចស្មានដល់។ (៤) ពេលចុះធ្វើការសម្របសម្រួលជាមួយជាមួយប្រជាពលរដ្ឋត្រូវមានឯកសារព្រោះពួកគាត់អាចយល់ព្រមនៅថ្ងៃនេះ ហើយបដិសេធនៅថ្ងៃក្រោយមានការផ្លាស់ប្ដូរវិញដោយកត្តាជំរុញពីខាងក្រោយ។

Draft

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ៥:១០ នាទីល្ងាច នៅថ្ងៃ ខែ ឆ្នាំ ដដែលក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងយោគយល់គ្នាខ្ពស់ ។

ធ្វើនៅកំពង់ធំ.ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១០

អ្នកធ្វើកំណត់ហេតុ

ហត្ថលេខា

Draft

## ឯកសារយោង


1. A Poverty Profile of Cambodia, MoP, 1997
2. Asia-Pacific Tropical Forestry: Ecological Disaster or Sustainable Growth, RAPA, Bangkok, 1994
3. Asian Development Bank. 1997. Involuntary Resettlement. *Operations Manual.* Manila. *Environment Division, Office of Environment and Social Development*. Manila.
4. ———. 2003. *Environmental Assessment Guidelines*. Manila.
5. Agricultural Strategies and Policy Framework for Sustainable Food Security and Poverty Alleviation, Cambodia, May 2000
6. Biodiversity the Life of Cambodia. Edited by Jady Smith, 2001
7. Cambodia Poverty Assessment, MoP, 1999
8. Cambodia Forestry Code of Practice for Harvesting dated 26 July 1999
9. Conflict and Natural Resource Management, FAO, 2000
10. FAO Model Code of Forest Harvesting Practice, Rome 1995
11. FAO Model Code of Forest Harvesting Practice, Rome 1996
12. Forest Concession Management Planning Manual, dated March 2001
13. Forest Inventory in Eastern Mekong by B. Rollet 1962
14. Forest Resources Assessment 1990, in Tropical Countries, FAO, Rome, 1993
15. General Population Census of Cambodia – Final Census Result of 1998
16. Gene-Ecological Zonation of Cambodia – Forestry Administration, DANIDA, German Development Services, December, 2003
17. Guidelines For Preliminary EIA for Forest Harvesting – 27 January 1995
18. Handbook of the Policy and Basic Procedure of EIA in Sarawak – 27 January 1995
19. Landuse Capability Map 1997/97
20. National Environmental Planning Manual 1998-2002
21. National Forest Policy of Cambodia, WB, UNDP, FAO, April 1996
22. National Weather Report From Ministry of Water Resource and Meteorology
23. Non-wood Forest Products for Rural Income and Sustainable Forestry, FAO, Rome, 1995
24. Royal Decree on the declaration of Protected Areas dated 1st November 1993
25. Satellite Imageries map interpreted by DFW year 1996/97/2000
26. Strategic Environmental Framework for the Greater Mekong Sub-region: Integrating Development and Environment in the Transport and Water Resource Sectors, Stockholm Environment Institute
27. Soil Survey Report of Charles D. Crocker 1962/63
28. The Atlas of Cambodia, National Poverty and Environmental Maps, DANIDA, 2006
29. Vegetation of Cambodia 1972 & 1996/97 and 2000.
30. DANIDA., 2003. Gene-Ecological Zonation of Cambodia. Cambodian Tree Seed Project Institute Capacity Building of the Tree Seed Sector. Forestry Administration. pp 19-25.


Draft